# ចម្លាក់ផ្តែរទ្វារព្រះវិស្ណុផ្ទុំនៅវត្តភ្នំតាំងស្រែ

*រឿងទេវកថាព្រះវិស្ណុផ្ទុំ ជារឿងដែលគេតែងឃើញញឹកញាប់ខ្លាំងនៅតាមចម្លាក់បុរាណរបស់ខ្មែរ ដែលមានតាំងពីស.វ.ទី៧មកម្ល៉េះ។ ក្នុងនោះ ចម្លាក់ព្រះវិស្ណុផ្ទុំដែលចាស់ជាងគេនៅក្នុងសិល្បៈខ្មែរ ទំនងជាចម្លាក់នៅលើផ្តែរទ្វារមួយដែលពីមុនមកគេរក្សាទុកនៅសហរដ្ឋអាមេរិក និងគ្រោងយកមកប្រទេសកម្ពុជាវិញនៅពេលខាងមុខ។ នៅក្នុងអត្ថបទខ្លីនេះ យើងសូមបង្ហាញផ្តែរទ្វារមួយដែលមានចម្លាក់ព្រះវិស្ណុផ្ទុំដូចគ្នា រកឃើញនៅវត្តភ្នំតាំងស្រែ ដែលស្ថិតនៅក្នុងឃុំតាំងក្រាំង ស្រុកបាធាយ ខេត្តកំពង់ចាម និងមានអាយុកាលនៅស.វ.ទី៧ ក្នុងរចនាបថព្រៃក្មេង រក្សាទុកនៅក្នុងរោងប្រក់ព្រះពុទ្ធរូបមួយនៅខាងលិចព្រះវិហារ (រូបលេខ១)។*

*មុននឹងរៀបរាប់អំពីលក្ខណៈទូទៅរបស់ចម្លាក់នៅលើផ្តែរ យើងសូមសង្ខេបអំពីសាច់រឿងទេវកថាព្រះវិស្ណុផ្ទុំជាមុនសិន។ រឿងនេះមានរៀបរាប់នៅក្នុងគម្ពីរ* Viṣṇu-Purāṇa *ដែលមានសេចក្តីសង្ខេបថា៖ "នៅពេលពិភពលោកទាំងមូលអាប់អួរ ការបំផ្លាញលោកចាស់ដើម្បីបង្កើតលោកថ្មីក៏ចាប់ផ្តើមឡើងដែលសង្ឃឹមថាលោកទាំងមូលថ្មីនឹងមានសភាពប្រសើរជាងមុន។ ក្នុងពេលនោះលោកទាំងមូលហ៊ុមព័ទ្ធដោយទឹកជំនន់យ៉ាងធំធេង ភ្លើងឆេះកល្បបំផ្លាញជីវិតសត្វនិងអ្វីទាំងអស់ដែលមាននៅលើលោក។ ព្រះវិស្ណុបានផ្ទុំលើនាគអនន្តដែលមានក្បាលសេស ហើយនៅពេលចុងបង្អស់នៃកល្ប ពិភពលោកក៏ប្រែក្លាយទៅជាទឹកសមុទ្រ ពេលនោះព្រះព្រហ្មក៏លេចចេញពីផ្ចិតព្រះវិស្ណុទ្រដោយផ្កាឈូក ក្នុងតួនាទីជាអ្នកបង្កើតលោកថ្មី"។[១]*

*លក្ខណៈទូទៅរបស់ផ្តែរទ្វារវត្តភ្នំតាំងស្រែមាន ៖ នៅខាងចុងសងខាងផ្តែរគេលម្អដោយរូបសត្វគ្រុឌ ដែលគេស្គាល់តាមរយៈគម្ពីរផ្សេងៗថាជាយានជំនិះរបស់ព្រះវិស្ណុ(រូបលេខ២)។ ការបង្ហាញរូបគ្រុឌបែបនេះ យើងធ្លាប់ឃើញនៅលើផ្តែរទ្វារដែលមានចម្លាក់ព្រះវិស្ណុផ្ទុំមួយទៀតនៅវត្តតាំងក្រសាំង ដែលស្ថិតនៅក្នុងឃុំតាំងក្រសាំង ស្រុកបាធាយ ដូចគ្នាដែរ (រូបលេខ៣) និងធ្លាប់បានសិក្សាយ៉ាងក្បោះក្បាយដោយលោក* Pierre Dupont *កាលពីឆ្នាំ១៩៥២*[២] *និងលោកស្រី* Mireille Bénisti *កាលពីឆ្នាំ១៩៦៥។*[៣] *ផ្នែកខាងក្រោមនៃផ្តែរ គេបង្ហាញរូបព្រះវិស្ណុផ្ទុំលើនាគអនន្ត មានក្បាលចំនួន ៧ មានព្រះហស្តចំនួន ៤ (ព្រះហស្តឆ្វេងម្ខាងដាក់សណ្តូកត្រង់ទៅក្រោម, ឆ្វេងម្ខាង*

---

[១] Wilson 1896: 18.

[២] Dupont 1952: 52.

[៣] Bénisti 1965: 93.

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

ទៀតដាក់សណ្ដូកនៅលើពោះ, ព្រះហស្តស្តាំម្ខាងដាក់ឡើងទៅលើទៅកៀកនឹងក្បាលនាគ និងស្តាំម្ខាងទៀតដាក់ច្រត់ព្រះសិរ) ស្មៀកសំពត់ខ្លីត្រឹមជង្គង់ដែលមានជាយនៅចំកណ្តាល (រូបលេខ២) នៅខាងចុងព្រះបាទមានចម្លាក់រូបនាគរាជ (Nãga Rãja) (រូបលេខ៥) និងនៅខាងលើព្រះសិរមានចម្លាក់ទេពស្រីដែលទំនងជាព្រះនាងលក្ស្មី (រូបលេខ៦)។ ចំណែកផ្នែកខាងលើនៃផ្តែរទ្វារគេឆ្លាក់ជាក្បាច់បន្ទាត់ផ្ទរាងត្រង់ដែលតួអង្គកណ្តាល គឺជារូបចម្លាក់ព្រះព្រហ្មអង្គុយក្នុងកាយវិការសមាធិនៅលើផ្កាឈូកដែលដុះចេញផ្ចិតព្រះវិស្ណុ (រូបលេខ៧) ហើយនៅអមសងខាងមានរូបទេពអង្គុយបញ្ឈរជង្គង់ម្ខាង ក្នុងទម្រង់មហារាជលីលាសន (Mahãrãjalīlãsana) ដែលទំនងជាតួអង្គ "មធុ" និង "កៃដភ" (រូបលេខ៨) ។ យើងកត់សម្គាល់ឃើញថា ចម្លាក់ព្រះវិស្ណុនៅលើផ្តែរវត្តភ្នំតាំងស្រែមានព្រះហស្តចំនួន ២ ដូចចម្លាក់រូបព្រះវិស្ណុផ្ទុំផ្សេងៗទៀតនៅស.វ.ទី៧ដូចគ្នាដែរ ហើយការលម្អគ្រឿងអលង្ការក៏ដូចគ្នាដែរ។ ប៉ុន្តែ ការឆ្លាក់រូបនាគរាជ (ស្តេចនាគ) នៅខាងចុងព្រះបាទរបស់ព្រះវិស្ណុ គឺជាទម្រង់មួយដែលចម្លាក់ផ្សេងៗទៀតនៅស.វ.ទី៧ដូចគ្នាពុំឃើញមានឡើយ ហើយការឆ្លាក់រូបនេះទំនងគេឆ្លាក់រូបតំណាងឱ្យទឹកសមុទ្រ ដ្បិតនាគតំណាងឱ្យទឹក ដែលខុសពីផ្តែរផ្សេងៗទៀតយើងឃើញគេឆ្លាក់ជារូបរលក និងរូបក្បាលសត្វមករនៅក្បែរព្រះកាយព្រះវិស្ណុដែលបញ្ជាក់ពីទឹកដូចគ្នា។ លើសពីនេះ ការឆ្លាក់រូបព្រះនាងលក្ស្មីនៅផ្នែកខាងលើព្រះសិរ ក៏ពុំធ្លាប់ឃើញមាននៅស.វ.ទី៧ដែរ តែយើងធ្លាប់ឃើញមាននៅខាងចុងព្រះបាទដូចឃើញនៅផ្តែរទ្វារប្រាសាទស្រីគ្រប់ល័ក្ខណ នៅតំបន់ប្រាសាទសំបូរព្រៃគុក (រូបលេខ៩)។

ជារួមមក ផ្តែរទ្វារចម្លាក់ព្រះវិស្ណុផ្ទុំនៅវត្តភ្នំតាំងស្រែ បង្ហាញឱ្យឃើញពីគំនិតរបស់បុព្វបុរសខ្មែរក្នុងការច្នៃសាច់រឿងទេវកថាដែលមាននៅក្នុងគម្ពីរឱ្យចេញជាចម្លាក់នៅលើថ្ម ដូចរឿងព្រះវិស្ណុផ្ទុំនេះជាដើម ដែលខ្មែរតែងអនុវត្តតាមគម្ពីរមាក៌ណ្ឌេយបុរាណ (Mārkaṇḍeya-Purāṇa)។ ចម្លាក់មួយចំនួននៅលើផ្តែរវត្តភ្នំតាំងស្រែ មានលក្ខណៈដូចចម្លាក់ព្រះវិស្ណុផ្ទុំនៅលើផ្តែរដទៃទៀតក្នុងស.វ.ទី៧ ប៉ុន្តែក៏មានផ្នែកខ្លះខុសគ្នាដែរ ជាក់ស្តែងដូចជា ការបង្ហាញរូបនាគរាជ (ស្តេចនាគ) នៅខាងចុងព្រះបាទព្រះវិស្ណុ និងការបង្ហាញរូបទេពស្រីគឺព្រះនាងលក្ស្មីនៅខាងលើព្រះសិរ។

## ឯកសារយោង


**Bénisti, M.**

1965, 'Répresentations Khmères de Viśṇu couché' in *Art Asiatiques*, Tome 11, Paris.

**Dupont, P.**

1952, 'Les Linteaux khmères du VIIe siècle' in *Artibus Asiae*, Vol 15, No. ½, Paris.

**Wilson, H.H.**

1896, *A Pros of English Translation of VishnuPuranam,* Edited and Published by Manmatha Nath Dutt, M.A., M.R.A.S., Calcutta.


អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ១៖ ផ្តែរទ្វារមានចម្លាក់ព្រះវិស្ណុផ្ទុំរកឃើញនៅវត្តភ្នំតាំងស្រែ ស្រុកបាធាយ ខេត្តកំពង់ចាម



រូបលេខ២៖ លម្អិតរូបគ្រុឌ



រូបលេខ៣៖ ផ្តែរទ្វាររកឃើញនៅវត្តតាំងក្រសាំង ស្រុកបាធាយ (ប្រភព៖ Dupont 1952)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៤៖ លម្អិតរូបព្រះវិស្ណុ



រូបលេខ២៥-៦៖ លម្អិតរូបនាគរាជ និងព្រះនាងលក្ស្មី



រូបលេខ២៧-៨៖ លម្អិតរូបព្រះព្រហ្ម និងទេពនៅអមសងខាងព្រះព្រហ្ម ទំនងជា មធុ និងកៃដក

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ៩៖ ផ្តែរប្រាសាទស្រីគ្រប់ល័ក្ខណ (ប្រភព៖ Bénisti, 1974)

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ម៉ង់ វ៉ាលី